ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ.........០៧.........ស.ភ.រ

# សេចក្តីជូនដំណឹង

សាលាភូមិន្ទរដ្ឋបាលសូមជម្រាបជូនដល់បេក្ខជនទាំងអស់ ដែលបានដាក់ពាក្យចូលរួមក្នុងការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី៩ ជ្រាបថា ការប្រឡងលើវិញ្ញាសាសរសេរនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ និងទី២៤ ខែមករា ឆ្នាំ២០១៦ នៅសាលាភូមិន្ទរដ្ឋបាល តាមកម្មវិធីដូចខាងក្រោម៖

**១- ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៦**

- ព្រឹក៖ ០៧:៣០ ដល់ម៉ោង ០៩:៣០ វិញ្ញាសាភាសាអង់គ្លេស ឬបារាំង
- រសៀល៖ ១៣:៣០ ដល់ម៉ោង ១៦:៣០ វិញ្ញាសាចំណេះដឹងទូទៅ។

**២- ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៦**

- ព្រឹក៖ ០៧:៣០ ដល់ម៉ោង ០៩:៣០ ដំណោះស្រាយតាមករណីសិក្សា
- រសៀល៖ ១៣:៣០ ដល់ម៉ោង ១៦:៣០ វិញ្ញាសាជំនាញ
    - សេដ្ឋកិច្ចកម្ពុជា និងពិភពលោក ឬ
    - ការរៀបចំដែនដី កំណែទម្រង់រដ្ឋបាលសាធារណៈ និងអភិបាលកិច្ចល្អនៅកម្ពុជា ឬ
    - ទំនាក់ទំនងអន្តរជាតិ នីតិសាធារណៈ និងអង្គការអន្តរជាតិ។

បេក្ខជនត្រូវមកដល់សាលាភូមិន្ទរដ្ឋបាល នៅវេលាម៉ោង៦ម៉៣០នាទី ព្រមទាំងត្រូវមាន៖

១- សលាកបត្រឯកត្តជន

២- ប៊ិចពណ៌ខៀវ និង/ឬបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

**បេក្ខជនមិនត្រូវបានអនុញ្ញាតឱ្យយកឯកសារ ទូរស័ព្ទ ឧបករណ៍អេឡិចត្រូនិកផ្សេងៗចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត។**

បេក្ខជនអាចចូលទៅក្នុងគេហទំព័ររបស់សាលា www.era.cambodia.gov.kh ដើម្បីទទួលព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការប្រឡងនេះ។

ចំពោះការប្រឡងវិញ្ញាសាភាសា បេក្ខជនដែលជ្រើសរើសភាសាបារាំង ត្រូវជូនដំណឹងដល់ទីចាត់ការសាលា ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ជាកំហិត។

សេចក្តីដូចបានជូនដំណឹងខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦

**នាយកសាលា**

**យក់ ប៊ុនណា**

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាព្រឹកផ្សេង (៤៦៦) ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh